# កំណត់ហេតុវគ្គបណ្តុះបណ្តាល

## ស្តីពី

## ជំនាញសម្របសម្រួល និងការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន

### ថ្ងៃទី ២៨ - ៣០ ខែសីហា ឆ្នាំ២០១៨ នៅភ្នំពេញ








នៅដាយកូនៀវសិនធើ ផ្ទះលេខ១៩-២១ផ្លូវលេខ៣៣០ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,Cambodia

| | |
|---|---|
| **សម្របសម្រួលដោយៈ** | **លោក ស៊ឹង ទីប៉ូ** អ្នកគ្រប់គ្រងផ្នែកអភិវឌ្ឍន៍សមត្ថភាព<br>**កញ្ញា កៅ ពៅលក្ខិណា** អ្នកឯកទេសផ្នែកអង្គការសហគមន៍មូលដ្ឋាន |
| **អ្នកកត់ត្រាចំនុចសំខាន់ៗៈ** | ស្រេង សោភ័ណលក្ខិណា |
| **ចំនួនអ្នកចូលរួមៈ** | • ចំនួនសរុបអ្នកចូលរួមៈ ២០ នាក់<br>• ចំនួនអង្គការសហគមន៍មូលដ្ឋាន ៖ ០៤នាក់<br>• ចំនួនអង្គការមិនមែនរដ្ឋាភិបាលៈ ០៩នាក់<br>• ចំនួនអង្គការ គ.ស.ក ៖០៧នាក់<br>• ចំនួនស្ត្រីៈ ០៧នាក់<br>(សូមមើលឧបសម្ព័ន្ធ ១ៈ សម្រាប់បញ្ជីវត្តមានសម្រាប់វគ្គបណ្តុះបណ្តាលទាំងបីថ្ងៃ) |
| **ថ្ងៃខែឆ្នាំ និង ពេលវេលា** | ថ្ងៃទី ២៨ - ៣០ ខែសីហា ឆ្នាំ២០១៨ ចាប់ពីម៉ោង ០៨៖០០ ព្រឹក – ០៥៖០០ ល្ងាច |
| **ទីកន្លែង** | ដាយកូនៀសិនធើ ផ្ទះលេខ១៩-២១ផ្លូវលេខ៣៣០ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ |

## គោលដៅចំបងៗវគ្គបណ្តុះបណ្តាលៈ

១. ដើម្បីធ្វើការបង្រៀនសាកល្បង និងឆ្លុះបញ្ចាំង ថាតើសៀវភៅជំនាញសម្របសម្រួល និងកម្រងមេរៀនស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាននេះ បានឆ្លើយតបទៅនឹងតម្រូវការកសាងសមត្ថភាពរបស់អង្គការសហគមន៍មូលដ្ឋាន ក៏ដូចជាអង្គការសង្គមស៊ីវិលដែលធ្វើការគាំទ្រដល់អង្គការសហគមន៍មូលដ្ឋានហើយឬនៅ។

២. ដើម្បីធ្វើការកែសម្រួលសៀវភៅជំនាញសម្របសម្រួល និងកម្រងមេរៀននេះ ឲ្យមានភាពងាយស្រួល និងឆ្លើយតបទៅនឹងតម្រូវការកសាងសមត្ថភាពរបស់អង្គការសហគមន៍មូលដ្ឋាន និង ដើម្បីឲ្យអង្គការសហគមន៍មូលដ្ឋានមានលទ្ធភាពក្នុងការប្រើប្រាស់គោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន។

(សូមមើលឧបសម្ព័ន្ធ ២ៈ សម្រាប់ឯកសារទស្សនទាន វគ្គបណ្តុះបណ្តាលសាកល្បង ស្តីពីជំនាញសម្របសម្រួល និងការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន)

## I- លទ្ធផលនៃវេទិកាសិក្សា

### ថ្ងៃទី ១៖ ថ្ងៃទី ២៨ សីហា ២០១៨

### ការណែនាំអំពីគោលបំណងនៃវគ្គបណ្តុះបណ្តាលរបស់អង្គការសហគមន៍មូលដ្ឋាន ដោយកញ្ញា កៅ ពៅលក្ខិណា អ្នកឯកទេសផ្នែកអង្គការសហគមន៍មូលដ្ឋាន

កញ្ញាបានណែនាំពីគោលបំណង និងរបៀបវារៈខ្លះនៃវគ្គបណ្តុះបណ្តាលរយៈពេលបីថ្ងៃ និងកញ្ញាបានអញ្ជើញ **លោកស្រី អែល សុធារី** ប្រធានផ្នែកកម្មវិធីនៃអង្គការ គ.ស.ក ថ្លែងសន្ទរកថាស្វាគមន៍។

### សន្ទរកថាស្វាគមន៍ និងបើកកម្មវិធី ដោយ លោកស្រី អែល សុធារី ប្រធានផ្នែកកម្មវិធីនៃអង្គការ គ.ស.ក




លោកស្រីបានស្វាគមន៍យ៉ាងកក់ក្តៅ និងអរគុណដល់សិក្ខាកាមដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ ហើយលោកសូមកោតសរសើរចំពោះក្រុមបច្ចេកទេសដែលបានចងក្រង សៀវភៅគោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន ដើម្បីឲ្យអង្គការសហគមន៍មូលដ្ឋានយល់ដឹង និងប្រើប្រាស់គោលការណ៍ណែនាំនេះប្រកបដោយប្រសិទ្ធិភាព អង្គការគ.ស.ក បានរៀបចំចងក្រងសៀវភៅជំនាញសម្របសម្រួល និងកម្រងមេរៀនស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន ហើយវគ្គបណ្តុះបណ្តាលនេះត្រូវបានរៀបចំឡើងជាការបង្រៀនសាកល្បង ទៅលើសៀវភៅជំនាញសម្របសម្រួល និងកម្រងមេរៀននេះ និងឆ្លុះបញ្ចាំង ថាតើសៀវភៅ នេះ បានឆ្លើយតបទៅនឹងតម្រូវការកសាងសមត្ថភាពរបស់អង្គការសហគមន៍មូលដ្ឋាន ក៏ដូចជាអង្គការសង្គមស៊ីវិលដែលធ្វើការគាំទ្រដល់អង្គការសហគមន៍មូលដ្ឋានហើយឬនៅ។

អង្គការគ.ស.ក សូមធ្វើជាចំណែកក្នុងការចូលរួមពង្រឹងសមត្ថភាពដល់អង្គការសហគមន៍មូលដ្ឋានរបស់លោកអ្នក ដោយរៀបចំវគ្គបណ្តុះបណ្តាលនេះទៅដល់អង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការគាំទ្រដល់អង្គការសហគមន៍មូលដ្ឋាន ហើយពួកគាត់នឹងបន្តបង្រៀនទៅដល់អង្គការសហគមន៍មូលដ្ឋានរបស់ពួកគាត់។ លោកស្រីបានបន្តថា ថ្មីៗនេះអង្គការ គ.ស.ក បានចុះអនុស្សរណៈជាមួយបណ្តាញអង្គការមិនមែនរដ្ឋាភិបាល តាមខេត្តចំនួន ១៥ ខេត្ត ហើយយើងនឹងផ្តល់ជូនវគ្គបណ្តុះបណ្តាលនេះក្នុងការពង្រឹងសមត្ថភាព និងផ្តល់ឱកាសឲ្យសមាជិកបណ្តាញអង្គការមិនមែនរដ្ឋាភិបាល ដើម្បីអោយពួកគាត់ជួយពង្រឹង


www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,Cambodia
Accountability GPP Symbol of Trust 25/08/2015 24/08/2018

សមត្ថភាពបន្តទៅដល់អង្គការសហគមន៍មូលដ្ឋានរបស់ពួកគាត់។ ជាចុងក្រោយ លោកស្រីបានថ្លែងអំណរគុណជាថ្មីម្តងទៀតដល់សិក្ខាកាមទាំងអស់ដែលបានចំណាយពេលវេលាមកចូលរួម និងពិភាក្សាក្នុងថ្ងៃនេះ ដើម្បី សិក្សា ក៏ដូចជាចែករំលែកនូវបទពិសោធន៍ សំដៅធ្វើយ៉ាងណាឲ្យការអភិវឌ្ឍកាន់តែប្រសើរឡើង។ ជាចុងបញ្ចប់លោកស្រី ក៏បានជូនពរទៅដល់សិក្ខាកាមទាំងអស់ និងប្រកាសបើកវគ្គបណ្តុះបណ្តាល។

## បទបង្ហាញជាទូទៅស្តីពី សៀវភៅជំនាញសម្របសម្រួល និងកម្រងមេរៀនស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន



ដើម្បីជាជំនួយស្មារតី និងផ្តល់ជាព័ត៌មានទូទៅស្តីពីវគ្គបណ្តុះបណ្តាលរយៈពេលបីថ្ងៃនេះ កញ្ញា កៅ ពៅលក្ខិណា អ្នកឯកទេសផ្នែកអង្គការសហគមន៍មូលដ្ឋាននៃអង្គការគ.ស.ក បានពន្យល់សង្ខេបដល់សិក្ខាកាមទាំងអស់នូវមេរៀនស្តីពី «សៀវភៅជំនាញសម្របសម្រួល និងកម្រងមេរៀនស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន»។ កញ្ញាចាប់ផ្តើមដោយការបង្ហាញពី៖

- សារតា
- បញ្ហាប្រឈមរបស់អង្គការសហគមន៍មូលដ្ឋាន
- កិច្ចអន្តរាគមន៍របស់អង្គការគ.ស.ក
- គោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន
- គោលបំណងក្នុងការបង្កើតគោលការណ៍ណែនាំនេះ
- មេរៀនក្នុងសៀវភៅជំនាញសម្របសម្រួល និងកម្រងមេរៀនស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន៖
  - ជំនាញសម្របសម្រួល
    - ការរៀបចំបរិបទនៃវគ្គបណ្តុះបណ្តាល
    - មូលដ្ឋានគ្រឹះនៃការសម្របសម្រួល
    - ជំនាញសម្រាប់ការសម្របសម្រួល
  - ការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន
    - លក្ខណៈផ្លូវច្បាប់ និងការអភិវឌ្ឍអង្គការសហគមន៍មូលដ្ឋាន
    - ទំនាក់ទំនង កិច្ចសហការ និងការចងបណ្តាញ
    - សមាជិកភាព និងការគ្រប់គ្រងសមាជិក



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,Cambodia

Accountability គណនេយ្យភាព
GPP
25/08/2015 24/08/2018
Symbol of Trust

- ការគ្រប់គ្រងហិរញ្ញវត្ថុ
- គណនេយ្យភាព និងតម្លាភាព
- ការចូលរួមអនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃ
- យុទ្ធសាស្ត្រ និងការធានានិរន្តរភាព
- ការពង្រឹងសមត្ថភាព និងការយល់ដឹង
- ភាពជាអ្នកដឹកនាំសហគមន៍

(សូមមើលឧបសម្ព័ន្ធ ៣៖ សម្រាប់បទបង្ហាញអំពីគោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន(

## ការសាកល្បងបង្រៀនជំនាញសម្របសម្រួលលើមេរៀន

### ការរៀបចំបរិបទនៃវគ្គបណ្តុះបណ្តាល សម្របសម្រួលដោយ លោក ស៊ឹង ទីប៉ូ អ្នកគ្រប់គ្រងផ្នែកអភិវឌ្ឍន៍សមត្ថភាព




- **ការណែនាំឲ្យស្គាល់គ្នា** (រយៈពេល ១០នាទី)

វគ្គនេះប្រើវិធីសាស្ត្រចាប់គ្នាជាគូរពីរនាក់ដើម្បីផ្លាស់ប្តូរព័ត៌មានគ្នាអំពី ឈ្មោះ តួនាទី ស្ថាប័ន និងខេត្តដែលពួកគាត់ធ្វើការ។ រួចហើយគូរទាំងពីរនាក់ នឹងឡើងនិយាយប្រាប់សិក្ខាកាមទាំងអស់អំពីដៃគូររបស់គាត់។

- **ការបង្កើតការរំពឹងទុកផ្ទាល់ខ្លួន និងការព្រួយបារម្ភ** (រយៈពេល ២០ នាទី)

❖ **ការរំពឹងទុករបស់អ្នកចូលរួម៖**

- ច្បាស់ពីជំហាននីមួយៗនៃការសម្របសម្រួល
- យល់ដឹងបន្ថែមពីជំនាញសម្របសម្រួលកាន់តែច្បាស់
- ទទួលបានបទពិសោធន៍បន្ថែមទៀតពីអ្នកសម្របសម្រួល និងសិក្ខាកាមដទៃទៀតពីជំនាញសម្របសម្រួល
- យល់កាន់តែច្បាស់ពីរបៀបប្រើប្រាស់ និងសម្របសម្រួលទៅលើគោលការណ៍ណែនាំពីការប្រត្តិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន
- អាចក្លាយជាអ្នកសម្របសម្រួល
- ទទួលបានធាតុចូលក្នុងន័យស្ថាប័នដើម្បីធ្វើឲ្យសៀវភៅកាន់តែមានអត្ថន័យ និងងាយស្រួលសម្រាប់អង្គការសហគមន៍មូលដ្ឋានយកទៅប្រើប្រាស់

❖ **ការព្រួយបារម្ភ**


www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009
#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,Cambodia
Accountability គណនេយ្យភាព GPP Symbol of Trust 25/08/2015 24/08/2018

- ចូលរួមមិនបានពេញលេញ
- ខ្លាចរៀនមិនសូវចេងចាំ
- មេរៀនច្រើន រៀនរយៈពេលតិច
- ពេលវេលាខ្លីសម្រាប់វគ្គបណ្តុះបណ្តាលក្នុងជំនាញនេះ

- **ការបង្កើតវិន័យសម្រាប់វគ្គបណ្តុះបណ្តាល** (រយៈពេល ១៥ នាទី)

  សិក្ខាកាមបានបង្កើតវិន័យសម្រាប់វគ្គបណ្តុះបណ្តាល ដែលមានដូចខាងក្រោម៖
  - ❖ បិទសម្លេងទូរស័ព្ទក្នុងម៉ោងសិក្សា។ ហាមនិយាយទូរស័ព្ទ លើកលែងតែករណីពិសេស ពេលនិយាយទូរស័ព្ទត្រូវចេញទៅខាងក្រៅថ្នាក់។
  - ❖ ហាមជជែកក្រៅប្រធានបទ បើគ្មានការអនុញ្ញាតិពីអ្នកសម្របសម្រួល ឬក្រុមធំ។
  - ❖ ចូលរួមរាល់ក្រុមពិភាក្សា ការពិភាក្សាក្រុមធំ ការសម្តែងរឿង និងល្បែងថាមពល។
  - ❖ គ្រប់ៗគ្នាត្រូវចូលរួមយោបល់ ហើយមុនការបញ្ចេញយោបល់ត្រូវលើកដៃ ដើម្បីមានភាពងាយស្រួលក្នុងការចាត់ចែង។
  - ❖ សិក្ខាកាមត្រូវអនុវត្តតាមការស្នើសុំរបស់អ្នកសម្របសម្រួល ដូចជាធ្វើលំហាត់ ឆ្លើយនឹងសំណួរ និងធ្វើផែនការ។
  - ❖ សិក្ខាកាមត្រូវគោរពពេលវេលាសិក្សារៀនសូត្រឲ្យបានល្អ ដោយអនុវត្តតាម ពេលព្រឹកចូលម៉ោង ៨ព្រឹក ចេញអាហារថ្ងៃត្រង់ម៉ោង១២។ ល្ងាចចូលម៉ោង ១.៣០ល្ងាច និងចេញម៉ោង៥ល្ងាច។
- **ការរៀបចំទីកន្លែង**

  ក្នុងវគ្គនេះលោកបានបង្ហាញពី វិធីរៀបចំទីកន្លែង និង បានពន្យល់ពីគុណសម្បត្តិ និងគុណវិបត្តិនៃការជ្រើសរើសរបៀបនៃការរៀបចំទីកន្លែងអង្គុយដែលមានដូចខាងក្រោម៖
- **ពេលវេលានៃការបណ្តុះបណ្តាល** (រយៈពេល ៤៥ នាទី)

អ្នកសម្របសម្រួលត្រូវស្វែងយល់ពីសកម្មភាពផ្ទាល់ខ្លួនរបស់សិក្ខាកាមម្នាក់ៗ ហើយការផ្លាស់ប្តូរវិធីសាស្ត្រត្រូវតែមានក្នុងករណីមានការផ្លាស់ប្តូរមិនប្រក្រតីណាមួយក្នុងចំណោមសិក្ខាកាម ដូចជា មានស្ងាប មើលម៉ោងជាញយៗ បង្ហាញទឹកមុខមិនចាប់អារម្មណ៍ ឬមិនអើពើជាដើម។ ដូច្នេះគួរតែផ្លាស់ប្តូរបរិយាកាស និងវិធីសាស្ត្រមកជាការសម្តែង ឬលេងល្បែងថាមពល ដែលពាក់ព័ន្ធទៅនឹងប្រធានបទ។

**មតិកែលំអ**

- ការណែនាំខ្លួន៖ គួរមានព័ត៌មានបន្ថែមទាក់ទងនឹងរបៀបណែនាំខ្លួន នូវវិធីសាស្ត្រនីមួយៗ ដែលមានរាយក្នុងសៀវភៅមេរៀន
- ការរៀបចំទីកន្លែង គួរមានចំណាំថា «ការរៀបចំទីកន្លែងអាចប្រែប្រួលទៅតាមគោលបំណង និងប្រភេទនៃកម្មវិធី ឬវគ្គបណ្តុះបណ្តាល»


www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,Cambodia
Accountability គណនេយ្យភាព
25/08/2015 GPP 24/08/2018
Symbol of Trust និមិត្តសញ្ញានៃភាពទុកចិត្ត

- កែអក្ខរាវិរុទ្ធ៖ ការប្រើប្រាស់វចនានុក្រម សម្តេចសង្ឃ ជួន ណាត
- តួលេខ៖ គួរសរសេរជាអក្សរចំពោះតួលេខ
- បន្ថែមដំណើរ មុន កំលុង និងក្រោយវគ្គ
- បទបញ្ហារផ្ទៃក្នុង អាចប្រើប្រាស់ថា គុណតម្លៃនៃវគ្គ ឬវិន័យសម្រាប់វគ្គ
- គួរមាននីតិវិធីនៃការវាយតម្លៃ ការស្ទង់ចំណេះដឹងមុនវគ្គ និងក្រោយវគ្គ
- ការរំពឹងទុក៖ អាចប្រើប្រាស់ថា «តើចង់បានអ្វីពេលត្រលប់ទៅវិញ?»
- គួរប្រើប្រាស់ភាសាតាមតំបន់ដើម្បីឲ្យងាយយល់

## មូលដ្ឋានគ្រឹះនៃការសម្របសម្រួល សម្របសម្រួលដោយ កញ្ញា កៅ ពៅលក្ខិណា អ្នកឯកទេសផ្នែកអង្គការសហគមន៍មូលដ្ឋាន

បានធ្វើបង្ហាញពីចំនុចសំខាន់នៃមេរៀនលើមាតិកាដូចខាងក្រោម៖

- **ទស្សនៈនៃការសម្របសម្រួល**
- **តួនាទីសំខាន់ របស់អ្នកសម្របសម្រួល ក្នុងពេលកំពុងតែដំណើរការសម្របសម្រួល**
- **អ្វីដែលត្រូវធ្វើ និងអ្វីដែលមិនត្រូវធ្វើ**



ក្នុងវគ្គនេះអ្នកសម្របសម្រួលបានបែងចែកជាក្រុមតូចជាបីក្រុមដោយមានការចាប់លេង ១ ២ ៣ ដែលមានចំនួនអ្នកចូលរួមស្មើគ្នា ដើម្បីពិភាក្សាលើប្រធានបទបី។ ខាងក្រោមជាលទ្ធផលនៃក្រុមពិភាក្សានីមួយៗ៖

**ក្រុមទី ១៖ តើតួនាទីសំខាន់ៗរបស់អ្នកសម្របសម្រួលមានអ្វីខ្លះ?**

តួនាទីសំខាន់ របស់អ្នកសម្របសម្រួល ក្នុងពេលកំពុងតែដំណើរការសម្របសម្រួលគឺ៖

- ☞ ឆ្លាតវៃចេះធ្វើការបត់បែន តាមកាលៈទេសៈ
- ☞ រៀបចំកិច្ចតែងការ
- ☞ រៀមចំសម្ភារៈ ទីកន្លែង កាលបរិច្ឆេទ
- ☞ ជូនដំណឹងអ្នកចូលរួម
- ☞ ផ្តល់ឱកាស និងបំផុសគំនិតលើកទឹកចិត្តឲ្យសិក្ខាកាមចូលរួមទាំងអស់គ្នា
- ☞ កំណត់ប្រភេទអ្នកចូលរួម
- ☞ ចេះផ្ទេរ និងចែករំលែកចំណេះ ជំនាញ និងបទពិសោធន៍ទៅអ្នកចូលរួម
- ☞ ចេះចាប់យកលទ្ធផល



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,Cambodia

Accountability
GPP
Symbol of Trust
25/08/2015
24/08/2018

☞ លើកទឹកចិត្តឲ្យសិក្ខាកាម វាយតម្លៃលើដំណើរការនៃការរៀនសូត្ររបស់ពួកគេដោយខ្លួនពួកគេផ្ទាល់។

**ក្រុមទី ២៖ តើអ្វីដែលអ្នកសម្របសម្រួលគួរធ្វើ និងមិនគួរធ្វើក្នុងពេលសម្របសម្រួល?**

| ត្រូវធ្វើ | មិនត្រូវធ្វើ |
|---|---|
| ទីកន្លែងសមរម្យ | មកយឺត |
| សម្ភារៈ អាកប្បកិរិយា | និយាយតែឯង |
| សំនួរបំផុលគំនិត | ប្រើភាសាបច្ចេកទេសច្រើនពេក |
| ធ្វើសំយោគ និងសរុបបទពិសោធន៍ថ្មីៗដែលបានរៀនសូត្រ | ប្រើអាកប្បកិរិយាមិនសមរម្យ |
| ចែកក្រុមពិភាក្សា | សន្និដ្ឋានគំនិតអ្នកចូលរួម |
| កំណត់ពេលវេលា | |
| ធ្វើជាអ្នកស្តាប់ដ៏ល្អ និងដោយយកចិត្តទុកដាក់ | |
| រៀបចំមេរៀន និង គោលបំណង ការរំពឹងទុក | |

**ក្រុមទី ៣៖ តើអ្នកសម្របសម្រួលគួរមានសមត្ថភាពអ្វីខ្លះ?**

- ជំនាញសម្របសម្រួល
- ជំនាញកត់ត្រា ស្តាប់
- សង្កេត និងសន្និដ្ឋាន
- ជំរុញ លើកទឹកចិត្ត
- ចេះបត់បែន និងដោះស្រាយបញ្ហា
- គ្រប់គ្រង និងដឹកនាំ
- សមត្ថភាពក្នុងការផ្ទេរចំណេះដឹង
- មានបទពិសោធន៍ពាក់ព័ន្ធបរិបទជាក់ស្តែងក្នុងប្រធានបទ

- **អាកប្បកិរិយារបស់អ្នកសម្របសម្រួល៖**

ក្នុងវគ្គនេះ សិក្ខាកាមឡើងសំដែងកាយវិការទៅលើប្រធានបទអាកប្បកិរិយារបស់អ្នកសម្របសម្រួល ជាបីប្រភេទ។

- **ការទទួលខុសត្រូវរបស់អ្នកសម្របសម្រួល**
- **ទម្រង់បែបបទដែលត្រូវអនុវត្ត ក្នុងពេលសម្របសម្រួល**



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009
#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,Cambodia

Accountability GPP Symbol of Trust 25/08/2015 24/08/2018

- បច្ចេកទេសក្នុងការសម្របសម្រួល និងល្បែងថាមពល
- ការសាកសួរ ពេលអនុវត្តលំហាត់ចប់

ក្នុងវគ្គនេះអ្នកសម្របសម្រួលបានបែងចែកក្រុមជាពីរក្រុមលើប្រធានបទដូចខាងក្រោម៖

**ក្រុមទី ១៖ តើអ្នកសម្របសម្រួលគួរធ្វើអ្វីខ្លះ មុន កំឡុង និងក្រោយពេលធ្វើការបណ្តុះបណ្តាល?**

☞ មុនការបណ្តុះបណ្តាល
- រៀបចំឯកសារ រៀបចំសម្ភារៈ កំណត់ទីកន្លែង កាលបរិច្ឆេទ
- ចំនួនអ្នកចូលរួម រៀបចំមេរៀន គោលបំណង ការរំពឹងទុក

☞ កំឡុងវគ្គបណ្តុះបណ្តាល
- តេស្តមុន ក្រោយវគ្គ បទបញ្ជាផ្ទៃក្នុង ចែកឯកសារ បំផុសគំនិត បែងចែកក្រុម កត់ត្រា
- សង្ខេប លេងល្បែង ផ្តល់យោបល់

☞ ក្រោយពេលធ្វើការបណ្តុះបណ្តាល
- កំណត់ហេតុ របាយការណ៍ តាមដានវាយតម្លៃ

**ក្រុមទី ២៖ តើបច្ចេកទេសក្នុងការសម្របសម្រួល និងល្បែងថាមពលមានអ្វីខ្លះ? និងគួរប្រើនៅពេលណាខ្លះ?**

| បច្ចេកទេសក្នុងការសម្របសម្រួល | ពេលវេលា |
|---|---|
| • បំបែកក្រុមពិភាក្សា<br>• បំផុសគំនិត/ផ្តល់ឧទាហរណ៍<br>• ពន្យល់ ពិព័ណ៌នា<br>• បទបង្ហាញ<br>• រំលឹកមេរៀន<br>• ប្រើឧបករណ៍ជំនួយ(រូបភាព Poster, LCD)<br>• ករណីសិក្សា<br>• ការសម្តែងរឿង ផ្សេងៗ | កំឡុងពេលបណ្តុះបណ្តាល<br>មុនពេលចូលប្រធានបទនីមួយៗ<br>ចុងថ្ងៃ ឬក្រោយចប់មេរៀន<br>តាមកាលៈទេសៈ |
| **ល្បែងថាមពល** | **ពេលវេលា** |


www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009
#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,Cambodia

| | |
|---|---|
| ដំឡូងក្តៅ លំហាត់ប្រាណ សុខសប្បាយ ចំរៀង<br><br>ការលេងល្បែងថាមពលនេះដើម្បីផ្សារភ្ជាប់ទំនាក់ទំនងមេរៀន បង្កើនភាពរីករាយ រំសាយភាពតាងតឹង | |

## ជំនាញសម្រាប់ការសម្របសម្រួល សម្របសម្រួលដោយ លោក ស៊ឹង ទីប៉ូ អ្នកគ្រប់គ្រងផ្នែកអភិវឌ្ឍន៍សមត្ថភាព

លោកបានធ្វើបង្ហាញពីចំនុចសំខាន់នៃមេរៀនលើមាតិកាដូចខាងក្រោម៖

- អនុវត្តការស្តាប់
- ឧបសគ្គនៅក្នុងការស្តាប់
- អ្វីដែលគួរធ្វើ និងអ្វីដែលមិនគួរធ្វើនៅពេលស្តាប់

(វិធីសាស្រ្ត ខ្លឹមសារ និង សកម្មភាពបង្រៀននៃមេរៀនទីមួយនេះមានរយៈពេល ៤៥ នាទីទាំងការប្ញូកបញ្ចូនការសម្របសម្រួលចម្លើយ)។

## ថ្ងៃទី ២៖ ថ្ងៃទី ២៩ សីហា ២០១៨

## រំលឹកមេរៀន និងការពិនាក្សាថ្ងៃទី១ សម្របសម្រួលដោយ លោកស្រី ស្រេង សោភ័ណលក្ខិណា ជំនួយការកម្មវិធីការអភិវឌ្ឍសមត្ថភាព

លោកស្រី បាននាំលេងល្បែងថាមពលដំឡូងក្តៅ ដើម្បីធ្វើការរំលឹកមេរៀននៅថ្ងៃទី១។

(វិធីសាស្រ្ត និង សកម្មភាពបង្រៀននៃមេរៀនទីមួយនេះមានរយៈពេល ២៥ នាទីទាំងការប្ញូកបញ្ចូនការសម្របសម្រួលចម្លើយ)

## ជំនាញសម្រាប់ការសម្របសម្រួល សម្របសម្រួលដោយ លោក ស៊ឹង ទីប៉ូ អ្នកគ្រប់គ្រងផ្នែកអភិវឌ្ឍន៍សមត្ថភាព (តមេរៀន)

- ការសួរដេញដោល

វគ្គនេះ **លោក ស៊ឹង ទីប៉ូ** បានប្រើសំនួរបំផុសគំនិតទៅសិក្ខាកាមអំពីរបៀបប្រើសំនួរដែលមានពីរប្រភេទ គឺសំនួរបើក ?អ្វី) ពេលណា( ?ដូចម្តេច ?កន្លែងណា ?នរណា ? និងសំនួរបិទ។ លោកបានស្នើសិក្ខាកាមធ្វើការអនុវត្តការសួរដេញដោលដោយធ្វើការជាក្រុម (បីក្រុម) ក្រុមនីមួយៗរើសតំណាងមួយដើម្បីអានរឿងអោយគេស្តាប់ ហើយអ្នកស្តាប់ចាប់ផ្តើមអនុវត្តការសួរដេញដោល ដើម្បីរកចម្លើយត្រឹមត្រូវ។ សំណួរល្បងប្រាជ្ញាមានក្នុងសៀវភៅជំនាញសម្របសម្រួល និងកម្រងមេរៀនស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន ក្នុងវិធីសាស្រ្តសម្របសម្រួល។



- **ការនិយាយឡើងវិញនូវគំនិតមួយដោយរក្សាន័យដើម**
- **ការផ្តល់យោបល់កែលំអ**

(វិធីសាស្រ្ត ខ្លឹមសារ និង សកម្មភាពបង្រៀននៃមេរៀនទីមួយនេះមានរយះពេល ១ម៉ោង ៥៥នាទីទាំងការប្តូកបញ្ជូនការសម្របសម្រួលចម្លើយ)។

**មេរៀនស្តីពីការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន លក្ខណ:ផ្លូវច្បាប់ និងការអភិវឌ្ឍអង្គការសហគមន៍មូលដ្ឋាន សម្របសម្រួលដោយ កញ្ញា កៅ ពៅលក្ខិណា អ្នកឯកទេសផ្នែកអង្គការសហគមន៍មូលដ្ឋាន**

- **ទស្សន:អំពីអង្គការសហគមន៍មូលដ្ឋាន**

**កញ្ញា កៅ ពៅលក្ខិណា** ចាប់ផ្តើមសម្របសម្រួលដោយពន្យល់ពីទស្សន:ទូទៅអំពីអង្គការសហគមន៍មូលដ្ឋាន រួចហើយបែងចែងសិក្ខាកាមជាបីក្រុម គឺក្រុមពណ៌ស ពណ៌បៃតង និងពណ៌ស្វាយ។
លទ្ធផលនៃការពិភាក្សាក្រុមមានដូចខាងក្រោម៖

**ក្រុមស៖ តើអង្គការសហគមន៍មូលដ្ឋានគឺជាអ្វី? ធ្វើការលើវិស័យណាខ្លះ? និងបង្កើតឡើងក្នុងគោលបំណងអ្វី?**

**ចម្លើយសំណួរទី១៖** អង្គការសហគមន៍មូលដ្ឋានជាក្រុមមនុស្សធ្វើការដោយស្ម័គ្រចិត្តក្នុងការរួមចំណែកធ្វើការអភិវឌ្ឍសហគមន៍មូលដ្ឋានដែលមានតាមប្រភេទដូចជា ក្រុមសន្សំ កសិកម្ម នេសាទ ដីធ្លី ព្រៃឈើ សិទ្ធកុមារ និង ស្រ្តី អនាម័យសុខភាព។


www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,Cambodia
Accountability GPP Symbol of Trust 25/08/2015 24/08/2018

**ចម្លើយសំណួរទី២៖** សារៈប្រយោជន៍នៃការចងក្រងអង្គការសហគមន៍មូលដ្ឋានរួមមាន ធ្វើអោយប្រសើរឡើងក្នុងការប្រើប្រាស់សិទ្ធក្នុងន័យទទួលបានជីវភាពធូរធារ និងដើម្បីពង្រឹងកិច្ចសហការ និងសាមគ្គីភាពជាមួយអ្នកពាក់ព័ន្ធ។

**ក្រុមស្វាយ៖ សារៈប្រយោជន៍នៃការចងក្រងអង្គការសហគមន៍មូលដ្ឋាន**

- មានសម្លេងរួម/សាមគ្គីភាព
- បណ្តុំធនធាន (មនុស្ស សម្ភារៈ ថវិកា)
- ងាយស្រួលគ្រប់គ្រងការអភិវឌ្ឍន៍
- មាននិរន្តភាព
- បង្កើនភាពជាម្ចាស់ និងការទទួលខុសត្រូវ
- កាត់បន្ថយហានិភ័យ និង បង្កើតភាពទុកចិត្ត
- ងាយស្រួលប្រមូលពត៍មាន តម្រូវការ ដោះស្រាយបញ្ហា
- មានជម្រើសមុខរបរ
- ទទួលបានឪកាស ការគាំទ្រ
- មានភាពស្របច្បាប់ក្នុងការអនុវត្តន៍ការងារ

**ក្រុមបៃតង៖ ដំណើរការនៃការបង្កើតអង្គការសហគមន៍មូលដ្ឋាន**

ដំណើរការក្នុងការបង្កើតអង្គការសហគមន៍មូលដ្ឋាន

- ប្រជុំពិគ្រោះយោបល់ជាមួយអ្នកពាក់ពន្ធ
- ស្នើរសុំការអនុញ្ញាតជាមួយអាជ្ញមូលដ្ឋាន & ពាក់ពន្ធ
- ប្រជុំដើម្បីបង្កើតអង្គការសហគមន៍មូលដ្ឋាន
- បោះឆ្នោតជ្រើសរើសគ ក គ្រប់គ្រាន់
- លក្ខន្តិកៈ បទបញ្ជាផ្ទៃ
- រៀបចំផែនការយុទ្ធសាស្រ្ត សមត្ថភាព ថវិកា និង ផែនការគ្រប់គ្រង
- អនុវត្ត ឆ្លុះបញ្ចាំង ត្រួតពិនិត្យ វាយតម្លៃ
- ផែនការយុទ្ធនិរន្តភាព

កញ្ញាបានបន្តការសម្របសម្រួលដោយធ្វើបទបង្ហាញលើចំណុចដូចខាងក្រោម៖

- **សារៈប្រយោជន៍នៃការចងក្រងអង្គការសហគមន៍មូលដ្ឋាន**
- **ទស្សនវិស័យ**
- **បេសកកម្ម**

- គុណតម្លៃ
- គោលដៅ
- គោលបំណង
- គណៈកម្មការរបស់អង្គការសហគមន៍មូលដ្ឋាន៖ កញ្ញា កៅ ពៅលក្ខិណា បានបែងចែកសិក្ខាកាមជាបីក្រុមដើម្បីពិភាក្សាលើតួនាទី និងការទទួលខុសត្រូវរបស់សមាជិកនៃគណៈកម្មការ៖

ក្រុមចេកពិភាក្សាលើតួនាទីប្រធាន និងអនុប្រធាន

- ប្រធាន
  - ទទួលខុសត្រូវ និងដឹកនាំទូទៅ
  - ដឹកនាំកិច្ចប្រជុំផ្សេងៗ (ការរៀបចំផែនការ)
  - ដោះស្រាយទំនាស់ និងវិវាងផ្សេងៗជូនសមាជិក
  - ត្រួតពិនិត្យ និងអនុម័យកិច្ចការរួម (ឯកសារផ្សេងៗ និងរបាយការណ៍)
  - ទំនាក់ទំនងខាងក្នុង និងខាងក្រៅ (ការរកមូលនិធីគាំទ្រ ការពង្រឹងសមត្ថភាពបណ្តាញការងារ
  - ធ្វើរបាយការណ៍របស់អង្គការជូនទៅក្រុមប្រឹក្សាភិបាល
- អនុប្រធាន
  - ជំនួយការប្រធាន
  - ដឹកនាំការប្រជុំពេលអវត្តមានប្រធាន/ផ្ទេរសិទ្ធិ
  - ធ្វើរបាយការណ៍ជូនប្រធាន
  - ធ្វើការទំនង់ទំនងខាងក្នុង និង ការក្រៅ(កិច្ចការប្រធាន)

ក្រុមស្វាយពិភាក្សាលើតួនាទីលេខា និង ហរិញ្ញឹក

- លេខា
  - កត់ត្រាកំណត់ហេតុរបាយការណ៍ប្រជុំ
  - រៀបចំលិខិតអញ្ជើញ
  - គ្រប់គ្រងឯកសារបញ្ជីចំណូលចំណាយ
  - រៀបចំផែនការគម្រោងផ្សេងៗ
  - ពិនិត្យឯកសារផ្សេងៗ
  - រៀបចំទីកន្លែងប្រជុំ និង កម្មវិធីផ្សេងៗ
  - ទទួលផែនការពីប្រធាន និងអនុប្រធាន
- ហេរញ្ញឹក
  - ពិនិត្យបញ្ជីចំណូលចំណាយ


www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009
#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,Cambodia
Accountability គណនេយ្យភាព
25/08/2015 GPP 24/08/2018
Symbol of Trust

- គ្រប់គ្រងថវិកាចំណូលចំណាយ និងបញ្ជីស្នាមផ្សេង
- រៀបចំគម្រោងសំណើរសកម្មភាពប្រចាំខែ
- រាប់ថវិកា និងទុកដាក់ថវិកា
- សម្របសម្រួលក្នុងដំណើរការសវនកម្ម (បើមាន)

ក្រុមល្អតពិភាក្សាលើតួនាទីសមាជិក , ក្រុមប្រឹក្សាភិបាល (យោបល់ និង អនុវត្ត)

➢ សមាជិក
  - ចូលរួមប្រជុំ ផ្សព្វផ្សាយបន្ត
  - អនុវត្តន៍តាមគោលការណ៍ លក្ខន្តិកៈ បទបញ្ជា
  - ចូលរួមធ្វើការផែនការ សកម្មភាព តម្រូវការ បញ្ហា
  - ចែករំលែកពត៌មាន បទពិសោធន៍ចំណេះដឹងដល់សមាជិក
  - ចូលរួមអនុវត្តសកម្មភាព
  - ចូលរួមតាមដាន

➢ ក្រុមប្រឹក្សាភិបាល អនុវត្ត
  - ចូលរួមបង្កើត ពិនិត្យ អនុម័តទៅលើគោលនយោបាយផ្សេងៗរបស់អង្គការសហគមន៍មូលដ្ឋាន
  - ចូលរួមដោះស្រាយបញ្ហាពេលដែលគណៈកម្មការដោះស្រាយមិនចេញ
  - ផ្សព្វផ្សាយពីអង្គការសហគមន៍មូលដ្ឋាន
  - ត្រួតពិនិត្យរបាយការណ៍ ផែនការ
  - ជួយរកថវិកា

➢ ក្រុមប្រឹក្សាភិបាលយោបល់
  - ជួយពិគ្រោះ និង ផ្តលយោបល់ទៅតាមការស្នើរសុំរបស់គណៈកម្មការ និងសមាជិក

(វិធីសាស្រ្ត ខ្លឹមសារ និង សកម្មភាពបង្រៀននៃមេរៀនទីមួយនេះមានរយៈពេល១ ម៉ោងទាំងការបូកបញ្ចូនការសម្របសម្រួលចម្លើយ)

## ថ្ងៃទី ៣៖ ថ្ងៃទី ៣០ សីហា ២០១៨

**រំលឹកមេរៀន និងការពិភាក្សាថ្ងៃទី២ សម្របសម្រួលដោយ លោកស្រី ស្រេង សោភ័ណលក្ខិណា ជំនួយការកម្មវិធីការអភិវឌ្ឍសមត្ថភាព**

លោកស្រី បានរំលឹកមេរៀននៅថ្ងៃទី២ ដោយអោយសិក្ខាកាមចាប់ក្រដាស់ដែលមានសំណួរនូវក្នុងនេះ។ (វិធីសាស្រ្ត និង សកម្មភាពបង្រៀននៃមេរៀនទីមួយនេះមានរយៈពេល ២៥ នាទីទាំងការបូកបញ្ចូនការសម្របសម្រួលចម្លើយ)

## ការពិភាក្សាលើមេរៀន សម្របសម្រួលដោយ កញ្ញា កៅ ពៅលក្ខិណា អ្នកឯកទេសផ្នែកអង្គការសហគមន៍មូលដ្ឋាន

កញ្ញាបែងចែកសិក្ខាកាមជាបីក្រុម ដើម្បីធ្វើការពិភាក្សាទៅលើមេរៀន ដូចខាងក្រោម៖



- ក្រុមទី១ ពិភាក្សាលើមេរៀន ទី២ ទី៣ និងទី៧
- ក្រុមទី២ ពិភាក្សាលើមេរៀន ទី៤ និងទី៥
- ក្រុមទី៣ ពិភាក្សាលើមេរៀន ទី៦ ទី៨ និងទី៩

ក្រុមទាំងបីនេះនឹងពិភាក្សាលើសំណួរពីរគឺ៖

១. តើខ្លឹមសារមេរៀន ឆ្លើយតបទៅនឹងចំណងជើងមេរៀនដែរឬទេ?

២. តើវិធីសាស្រ្ត សម្ភារៈបង្រៀន និងពេលវេលា ឆ្លើយតបទៅនឹងខ្លឹមសារមេរៀនដែរឬទេ?

លទ្ធផលរួមនៃការពិភាក្សាមានដូចខាងក្រោម

- ដាក់ក្រុមគោលដៅនៅផ្នែកណាមួយនៃសៀវភៅជារួមតែម្តង
- ដាក់ពេលវេលាសរុបសម្រាប់មេរៀននីមួយៗ
- ពន្យល់ពីគោលបំណងក្នុងការប្រើប្រាស់វិធីសាស្រ្តក្នុងការបង្រៀនក្នុងផ្នែកនីមួយៗ
- គួរកែសម្រួលឃ្លាឡើងវិញ
- វិធីសាស្រ្តមានជាន់គ្នាច្រើន ជាពិសេស)វិធីសាស្រ្តបង្រៀនក្នុងការពន្យល់ពាក្យ(
- និយមន័យនៃពាក្យមួយៗ គួរស្វែងរកនិយមន័យមកពីប្រភពផ្សេងៗ និងមានដាក់ព័ត៌មានពីឯកសារយោងទាំងនោះ



- អក្ខរាវិរុទ្ធ
- ឃ្លាចាំបាច់មួយចំនួនដែលដកស្រង់ចេញពីសៀវភៅផ្សេងៗគួរមានលេខយោង
- រូបភាពចាំបាច់តាមមេរៀនមួយៗគួរតែដាក់បញ្ចូល ដើម្បីជំនួយដល់អ្នកសម្របសម្រួល និងសិក្ខាកាម
- សម្ភារៈសម្រាប់បង្រៀនគួរដាក់តាមផ្នែកនីមួយៗនៃមេរៀន
- កែសម្រួលគោលបំណងក្នុងមេរៀននីមួយៗ
- តួលេខគួរសរសេរជាអក្សរ


www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009
#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,Cambodia

- គួរបន្ថែមរូបភាព
- គួរគិតពីវិធីសាស្រ្ត ឬបែងចែកមេរៀនសម្រាប់គ្រូបង្គោល និងអង្គការសហគមន៍មូលដ្ឋាន
- គួរស្វែងយល់ភាសាតាមតំបន់ និងជៀសវាងការប្រើប្រាស់ភាសាបច្ចេកទេស និងនិយាយលាយជាមួយភាសាបរទេស។
- លើកឧទាហរណ៍គួរតែជារឿងកើតឡើងនៅក្នុងសហគមន៍
- សូមអោយការបង្រៀនទ្រឹស្តីតិចជាងការអនុវត្តជាក់ស្តែង
- ដាក់សន្ទានុក្រមនៅពីមុខ ឬក្រោយមេរៀន
- ពន្យល់ពាក្យបំព្រួញកាត់

**ផែនការកសាងសមត្ថភាពបន្តអំពីវគ្គបណ្តុះបណ្តាល សម្របសម្រួលដោយ កញ្ញា កៅ ពៅលក្ខិណា អ្នកឯកទេសផ្នែកអង្គការសហគមន៍មូលដ្ឋាន**

សិក្ខាកាមត្រូវបានបែងចែកជាបីក្រុមដើម្បីពិភាក្សាលើផែនការកសាងសមត្ថភាពបន្តអំពីវគ្គបណ្តុះបណ្តាលដោយពិភាក្សាលើសំណួរបីសំខាន់ៗ។ សំណួរ និងលទ្ធផលនៃកិច្ចពិភាក្សាមានដូចខាងក្រោមៈ

**១.តើវគ្គបណ្តុះបណ្តាលនេះគួររៀបចំយ៉ាងដូចម្តេច ដើម្បីឲ្យគ្រូបដណ្តប់មេរៀន និងមានពេលគ្រប់គ្រាន់សម្រាប់ការសិក្សាសម្រាប់រ ?យៈពេលប៉ុន្មានថ្ងៃ? គួររៀបចំឡើងនៅពេលណា?**

**ចម្លើយៈ វគ្គបណ្តុះបណ្តាលនេះគួរបែងចែកជាបីវគ្គៈ**

- វគ្គទី១ អ្នកសម្របសម្រួល(៣ថ្ងៃ)
- វគ្គទី២ មេរៀនទី១ ដល់ ទី ៤ (៣ថ្ងៃ)
- វគ្គទី៣ មេរៀនទី៥ ដល់ ទី ៩ (៣ថ្ងៃ)

សម្រាប់ពេលវេលានៃវគ្គបណ្តុះបណ្តាល អង្គការគ.ស.ក គួរពិគ្រោះយោបល់ជាមួយអង្គការដៃគូរ

**២.តើអ្នកណាខ្លះអាចចូលរួមវគ្គនេះបាន)?លក្ខខណ្ឌអ្នកចូលរួម(**

**ចម្លើយៈ**

- បុគ្គលិកគម្រោង (អ្នកធ្វើការផ្ទាល់ជាមួយសហគមន៍)
- បណ្តាញអង្គការសហគមន៍មូលដ្ឋាន
- ជនបង្គោលថ្នាក់ខេត្ត

**៣. តើស្ថាប័នអ្នកមានបំណងនឹងបង្រៀនបន្តទៅអង្គការសហគមន៍មូលដ្ឋាននៅពេលណាតើត្រ ?ូវការគាំទ្រផ្នែកបច្ចេកទេសអ្វីខ្លះពីអង្គការ គ.ស.ក?**

**ចម្លើយៈ**



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009
#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,Cambodia

Accountability GPP Symbol of Trust 25/08/2015 24/08/2018

- វគ្គបណ្តុះបណ្តាលនេះនឹងបង្រៀនបន្តបន្ទាប់ពីបញ្ចប់វគ្គហើយ ផ្អែកលើកញ្ចប់ថវិការបស់អង្គការសាមុី។ តែបើអត់ថវិកានឹងព្យាយាមបញ្ជ្រាបមេរៀនចូលក្នុងកម្មវិធី
- អង្គការ គ.ស.ក គួរតែជួយជាសម្ភារ: (មេរៀន និងសៀវភៅ) និងធនធានមនុស្ស

## សន្ទរកថាបិទ ដោយលោក សឿង សារឿន នាយកប្រតិបត្តិអង្គការ គ.ស.ក

**លោក សឿង សារឿន** បានថ្លែងអំណរគុណ និងលើកសរសើរដល់សិក្ខាកាមដែលបានចូលរួម និងពិភាក្សាផ្តល់គំនិតយោបល់ក្នុងវគ្គបណ្តុះបណ្តាលសាកល្បងនេះ ដើម្បីយកជាគំនិតរួមកែសម្រួល សៀវភៅជំនាញសម្របសម្រួលមួយនេះក្នុងការពង្រឹងអង្គការដៃគូ ជាពិសេសអង្គការសហគមន៍មូល។ តែការយល់ដឹង និង ទទួលបានវាអាស្រ័យលើចំណេះដឹង និងសមត្ថភាពរបស់សិក្ខាកាមម្នាក់ៗ។ អង្គការ គ.ស.ក នឹងបង្រៀនគ្រូបង្គោលរបស់អង្គការមិនមែនរដ្ឋាភិបាលដែលជាដៃគូរ ហើយប្រសិនបើអង្គការដៃគូរខ្វះខាតថវិកា ឬធនធានផ្សេងៗ សម្រាប់បង្រៀនបន្តដល់អង្គការសហគមន៍មូលដ្ឋាន ហើយត្រូវការកញ្ចប់ថវិកាដើម្បីបង្រៀនបន្តនោះ ខាងអង្គការ គ.ស.ក នឹងផ្តល់ការគាំទ្រ។ ម៉្យាងទៀតអង្គការ គ.ស.ក មានប្រព័ន្ធរៀនសូត្រតាមអ៊ីនធឺណេត និងក្រុម Facebook របស់អង្គការសហគមន៍មូលដ្ឋាន។ លោកក៏បានជូនពរដល់សិក្ខាកាម ទាំងអស់មានសុខភាពល្អ និង សំណាងល្អ។




## មតិត្រលប់ និងសំណូមពរក្នុងវគ្គបណ្តុះបណ្តាល

យោងតាមលទ្ធផលនៃការវាយតម្លៃវគ្គបណ្តុះបណ្តាលនេះបានបង្ហាញថា ជារួមសិក្ខាកាមទាំងអស់មានការចាប់អារម្មណ៍និងពេញចិត្តចំពោះវគ្គបណ្តុះបណ្តាលនេះ រួមមាន ទីកន្លែង និងការផ្តល់ភស្តុភា ។

## សំណូមពរ

- គួរតែមានវិធីសាស្រ្តអនុវត្តជាក់ស្តែងបន្ថែមក្នុងកំឡុងពេលវគ្គនីមួយៗ
- សូមឲ្យពេលវេលា និងខ្លឹមសារមេរៀនសុីសង្វាក់គ្នា



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,Cambodia

Accountability គណនេយ្យភាព
GPP
25/08/2015 24/08/2018
Symbol of Trust

- សូមឲ្យពេលវេលា ពិភាក្សាក្រុមគ្រប់គ្រាន់
- ការបណ្តុះបណ្តាលគ្រូបង្គោល សិក្ខាកាមគួរចូលរួមឲ្យបានពេញលេញដើម្បីទទួលបានចំណេះដឹងពិតប្រាកដហើយបណ្តុះបណ្តាលបន្តទៅមុខទៀតប្រកបដោយគុណភាព
- គួរព្យាយាមសង្ខេបខ្លឹមសារអោយបានខ្លីធ្វើដែលអាចទទួលយកបាន និងប្រើប្រាស់ពាក្យសាមញ្ញ ប្រសិនបើប្រើប្រាស់ពាក្យបច្ចេកទេសគួរតែដាក់តែជួយបកស្រាយនៅក្នុងអត្ថបទ។

## ឧបសម្ព័ន្ធ

១. បញ្ជីវត្តមានសម្រាប់បីថ្ងៃ

២. ឯកសារទស្សនទាន និងរបៀបវារ:

៣. បទបង្ហាញអំពីគោលការណ៍ណែនាំ



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,Cambodia